# សប្តាហ៍នៃការសម្អាត

សប្តាហ៍នៃការសម្អាត ជាយុទ្ធនាការមួយដែលបង្កើតឡើងដោយកម្មការិនី កម្មកររោងចក្រកាត់ដេរ។ យុទ្ធនាការនេះផ្តោតទៅលើការសម្អាតបរិស្ថានជុំវិញកន្លែងរស់នៅ ក៏ដូចជាការសម្អាតបន្ទប់ទឹករួម និងបង្គន់រួមរបស់កម្មការិនីកម្មករ។

បន្ទាប់ពីធ្វើការសិក្សាស្រាវជ្រាវអំពីលក្ខខណ្ឌរស់នៅរបស់ កម្មការិនី កម្មករ ក្រោមប្រធានបទ«ជាតុពិតនៃឆ្អឹងខ្នងសេដ្ឋកិច្ចជាតិ» ក្រុមអ្នកស្រាវជ្រាវ ដែលជាកម្មការិនីកម្មករ បានរកឃើញថា ក្នុងចំណោមអ្នកផ្តល់បទសម្ភាសន៍ (កម្មការិនី) ៧៥នាក់ មាន ៤៣ភាគរយបានប្រើប្រាស់បង្គន់រួម។ នៅក្នុងនោះផងដែរ បង្គន់រួម ៤៨,៥ភាគរយ គឺមិនមានជំបូលប្រក់ពីលើត្រឹមត្រូវ គ្មានអនាម័យ មានសត្វរុយតាមរោម និងមានក្លិនអាក្រក់ចេញពីបង្គន់ ពេលខ្លះមានលាមកអណ្តែតទៀតផង។

នៅក្នុងការសិក្សាស្រាវជ្រាវនេះដែរ កម្មការិនី កម្មករ ៣៣,៣ភាគរយ(ក្នុងចំណោមកម្មការិនី កម្មករ ផ្តល់បទសម្ភាសន៍ ៧៥នាក់) បានឆ្លើយតបថា ពួកគាត់បានទុកសំរាមចោលនៅទីសាធារណៈ។ ការចោលសំរាមនៅទីសាធារណៈ បានធ្វើឲ្យប៉ះពាល់ខ្លាំងដល់បរិស្ថាន ប៉ុន្តែពួកគាត់អះអាងថា ដោយសារតែគ្មានកន្លែងចោលសំរាមត្រឹម







» តទៅទំព័រ ៣

បោះពុម្ពផ្សាយដោយ

អាសយដ្ឋាន: ផ្ទះលេខ៣-៤ ផ្លូវលេខ៣៣៩ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
លេខទូរស័ព្ទ: ០១៧ ២២៩ ៥០០
អ៊ីមែល: communication.wic@gmail.com
គេហទំព័រ: www.wic.unitedsisterhood.org



ព្រឹត្តិបត្រ
ចេញផ្សាយខែធ្នូ ឆ្នាំ២០១៧

ទំព័រកម្មករ
ឆ្អឹងខ្នងសេដ្ឋកិច្ចជាតិ វីរភាពគួរចងចាំ

លេខទី ៧-៨

# កម្មការិនី កម្មករ និងភាពច្នៃប្រឌិត



សម្ព័ន្ធបងប្អូនស្រី ដែលមានសមាគមក្រុមតន្ត្រីយុវវ័យនាំសារ សមាគមមណ្ឌលព័ត៌មានកម្មករ អង្គការបណ្តាញការងារស្ត្រីរួបរួមគ្នា និងសកម្មភាពសង្គមដើម្បីការផ្លាស់ប្តូរ កាលពីថ្ងៃពីថ្ងៃទី១២ វិច្ឆិកា ២០១៧ បានផ្តួចផ្តើមរៀបចំវេទិកាសិល្បៈស្ត្រីក្រោមប្រធានបទ «ពីក្រោយផ្ទាំងសំពត់ស» នៅសាលមហោស្រពចេនឡា។

ស្របតាមស្ថានភាពបច្ចុប្បន្ន និងយោងតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលដំណាក់កាលទី៣ ថ្នាក់ដឹកនាំបានបន្តប្តេជ្ញាធ្វើឲ្យប្រសើរឡើងនូវស្ថានភាពស្ត្រីដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិ តាមរយៈការអនុវត្តការលើកកម្ពស់សមភាពយេនឌ័រ។ រដ្ឋាភិបាលបានផ្តោតជាសំខាន់លើការចូលរួមរបស់ស្ត្រី ដើម្បីពន្លឿនការសម្រេចគោលដៅជាតិដូចជា ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តភាព និងចំណែកស្មើភាពសម្រាប់ស្ត្រី។ ទោះបីជាស្ត្រីជាផ្នែកមួយដ៏សំខាន់ក្នុងការអភិវឌ្ឍជាតិក៏ដោយ ប៉ុន្តែជារឿយៗ ផ្នត់គំនិត និងឥរិយាបថយេនឌ័រនៅតែបន្តដាក់គំនាប និងរារាំងការចូលរួមពេញលេញរបស់ស្ត្រីក្នុងគ្រប់វិស័យ។ ដោយមើលឃើញពីបញ្ហានៅក្នុងសង្គមទាំងនេះហើយទើបបង្កើតឲ្យមានវេទិកាសិល្បៈស្ត្រីនេះឡើង ដែលមានគោលបំណងសំខាន់ៗបី៖ ទីមួយបង្ហាញពីទំនាក់ទំនងរវាងផ្នត់គំនិត ឥរិយាបថសង្គម និងទស្សនៈវប្បធម៌ ប្រពៃណី ជាមួយសិទ្ធិនឹងតួនាទីស្ត្រីនៅក្នុងវិស័យផ្នែកសេដ្ឋកិច្ច សង្គម និងនយោបាយ តាមរយៈទម្រង់សិល្បៈចម្រុះ។ ទីពីរផ្សារភ្ជាប់ជាមួយក្រុមសិល្បករ សិល្បការិនីវ័យក្មេង និងអ្នកដែលមានអាជីពក្នុងវិស័យសិល្បៈ ដើម្បីបង្ហាញនូវទេពកោសល្យ និងឥទ្ធិពលនៃសិល្បៈ ក្នុងការកែប្រែការគិត។ គោលបំណងទីបី គឺជាឱកាសក្នុងការកសាងទំនាក់ទំនង និងសាមគ្គីភាពនៅក្នុងចលនាស្ត្រីដើម្បីបញ្ចេញនូវសំឡេង និងតម្រូវការរបស់ស្ត្រីនៅក្នុងការធ្វើការរួមគ្នាស្វែងរកដំណោះស្រាយ។

វេទិកាសិល្បៈស្ត្រីបានបង្ហាញពីទស្សនីយភាពសិល្បៈចម្រុះ ដោយមានការចូលរួមពីក្រុម សិល្បករ សិល្បការិនី ពោរពេញដោយទេពកោសល្យ និងភាពច្នៃប្រឌិត បង្ហាញពីតម្លៃនៃសិល្បៈផ្សារភ្ជាប់នឹងបញ្ហាសង្គម ជាពិសេសបញ្ហាដែលស្ត្រីជួបប្រទះក្នុងសង្គម និងគ្រួសារ។ ទម្រង់សិល្បៈទាំងនោះមានដូចជា ឆៃយ៉ាំ អាយ៉ៃ ល្ខោនខ្លី ល្ខោនសៀក របាំសហសម័យ និងចម្រៀង។ លើសពីនេះទៀត ក៏មានការតាំងពិព័រណ៍បង្ហាញពីស្នាដៃគំនូរ និងរូបភាពច្នៃប្រឌិតផ្សេងៗ។ ស្នាដៃគំនូរ និងរូបភាពច្នៃប្រឌិតទាំងនោះ គឺបង្កើតដោយកម្មការិនីកម្មករ ស្ត្រីប្រកបរបរផ្លូវភេទ កសិករ និងយុវជនវ័យក្មេង ដែលបានស្រុះស្រួលគ្នាយ៉ាងសស្រាក់សស្រាំក្នុងការធ្វើវាឡើង។

វេទិកានេះក៏មានការអញ្ជើញចូលរួមពី

» តទៅទំព័រ ៣



# សេចក្ដីសង្ឃឹមតាមរយៈភាពជាអ្នកដឹកនាំស្ត្រី



សមាគមមណ្ឌលព័ត៌មានកម្មករ គឺជាកន្លែងដែលផ្ដល់ចំណេះដឹង ប្រឹក្សាយោបល់ លើកទឹកចិត្ត និងពង្រឹងភាពម្ចាស់ការរបស់ស្ត្រីឲ្យក្លាយទៅជាអ្នកដឹកនាំ ក៏ដូចជាការចូលរួមសកម្មភាពតស៊ូមតិផ្សេងៗ នៅក្នុងសហគមន៍។

បន្ទាប់ពីទទួលបានការបណ្ដុះបណ្ដាលពីសមាគមមណ្ឌលព័ត៌មានកម្មករ នៅក្នុងចំណោមកម្មការិនី កម្មករ ជាច្រើនមានកម្មការិនីបីរូបរួមមានកញ្ញា ជា សារ៉ាត កញ្ញា សុត ផង និងអ្នកស្រី ទាវ ចាន់ណា ដោយពួកគាត់មានភាពក្លាហានក្នុងការឈរឈ្មោះធ្វើជាតំណាងកម្មករនៅក្នុងរោងចក្រខេមបូខូថប អិលធីឌី។ កត្តាសំខាន់ដែលធ្វើឲ្យពួកគាត់ឈរឈ្មោះ ដោយសារចង់ដឹងពីតួនាទីតំណាងកម្មករ និងមានភាពឈឺចាប់ចំពោះការកេងប្រវ័ញ្ចកម្លាំងពលកម្ម ក៏ដូចជាការរំលោភសិទ្ធិការងារដែលកើតមាននៅក្នុងវិស័យនេះ។ កម្មការិនី ទាវ ចាន់ណា៖ «ពួកយើងធ្វើការមួយថ្ងៃៗស្ទើរតែមិនបានទៅបន្ទប់ទឹកព្រោះតែការកំណត់ចំនួនច្រើន បើដេរមិនបានមានការហៅប្រជុំស្ដីឲ្យ ហើយប្រៀបធៀបយើងទៅក្រុមផ្សេងដែលដេរម៉ូដដូចគ្នាថា ដៃពីរជើងពីរដូចគេដែរមិនចេះខ្មាស់គេ គេធ្វើបានម៉េចយើងមិនបាន»។

ជាមួយគ្នានេះដែរ កម្មការិនី ជា សារ៉ាត់ ដោយសារចង់ដឹងអំពីរចនាសម្ព័ន្ធនៅក្នុងការដោះស្រាយវិវាទនៅក្នុងរោងចក្រ និងធ្វើការផ្លុះបញ្ចាំង តើហេតុអ្វីការទាមទាររបស់កម្មករតែងតែមិនទទួលបានដំណោះស្រាយ ជាពិសេសគឺការកំណត់ចំនួនច្រើន។ នាងបានលើកឡើងថា៖ «កន្លងមកនៅចុងឆ្នាំ ២០១៥ កម្មករបាននាំគ្នាតវ៉ាសុំបញ្ចុះចំនួនកំណត់ពី ៤៥០ ក្នុងមួយម៉ោង មកត្រឹម ៤០០ (អាវវាលក្លៀក walmart) ដោយមានការដឹកនាំពីសហជីព និងតំណាងកម្មករហើយការទាមទារនេះបានប្រហែលត្រឹម១ខែជាងប៉ុណ្ណោះក្រោយមកចំនួននោះក៏ឡើងវិញដដែល»។ មិនខុសពីកម្មការិនីទាំងពីរនាក់ខាងលើ សុត ផង ក៏មានគោលបំណងចង់ជួយដល់ខ្លួនឯង និងកម្មករផ្សេងទៀតឲ្យមានលក្ខខណ្ឌការងារល្អទើបនាងសម្រេចចិត្តឈរឈ្មោះជាតំណាងកម្មករនេះ។

កម្មការនី សុត ផង៖ «ខ្ញុំទទួលបានចំណេះដឹងច្រើនពីមណ្ឌលទាក់ទងនឹងច្បាប់ស្ដីពីការងារ ហើយខ្ញុំចង់យកចំណេះទាំងនេះទៅអនុវត្ត ឬទៅចចារជាមួយប្រធានរដ្ឋបាល ឬថៅកែ នៅពេលដែលមានការបំពាន ឬរំលោភសិទ្ធិណាមួយទៅលើកម្មករ និងធ្វើ





ការជាមួយកម្មករដើម្បីឲ្យប្រាកដថា ក្រុមហ៊ុនមានការគោរពច្បាប់ស្ដីពីការងារ និងសិទ្ធិកម្មករ»។

គួរបញ្ជាក់ថា បន្ទាប់ពីការទាមទាររបស់កម្មករដែលដឹកនាំដោយសហជីព និងតំណាងកម្មករគឺ ទទួលបានត្រឹមតែមួយខែប៉ុណ្ណោះ ក្រោយមកមានការមិនសុខចិត្តទៅនឹងការដំឡើងចំនួនកំណត់វិញ ហេតុដូច្នេះនៅខែមីនា ឆ្នាំ២០១៧ មានកម្មករមួយចំនួនប្រមាណជា២០នាក់ បាននាំគ្នាជជែកពិភាក្សារកវិធីសាស្ត្រក្នុងការដោះស្រាយបញ្ហានៅក្នុងដំណើរការនោះ កម្មការិនី ជា សារ៉ាត់ ទាវ ចាន់ណា និង សុត ផង បានដើរតួយ៉ាងសកម្មក្នុងការគៀងគរកម្មករពិភាក្សា ក៏ដូចជាការប្រមូលព័ត៌មានផ្សេងៗ។ ប៉ុន្តែដោយសារការបាត់បង់ជំនឿចិត្ត ចំពោះស្ថានភាពកន្លងមក ទើបធ្វើឲ្យខ្វះការចូលរួមពីកម្មករ ហើយ ស្របពេលដែលមានការផ្លាស់ប្ដូរម៉ូតខោអាវថ្មី ដំណើរការដោះស្រាយរបស់ពួកគេមិនទទួលបានលទ្ធផលអ្វីទេ។

នៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១៧ ក្រុមហ៊ុនបានរៀបចំការបោះឆ្នោតជ្រើសរើសតំណាងកម្មករ បន្ទាប់ពីបានដឹងអំពីការជូនដំណឹងពីក្រុមហ៊ុនតាមរយៈការបិទប្រកាស

» តទៅទំព័រ ៣





**« កម្មការិនី កម្មករ...**

លោកជំទាវ ម៉ិញ កុសនី អនុរដ្ឋលេខាធិកានៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ លោកជំទាវ គឹម ស៊ីផាត់ អគ្គនាយកនៃនាយកដ្ឋានសមភាពយេនឌ័រ និងអភិវឌ្ឍន៍សេដ្ឋកិច្ចនៃក្រសួងកិច្ចការនារី អង្គការដៃគូ និងសាធារណជនប្រមាណ ៦០០នាក់ តាមរយៈការចូលរួមវិភាគទាន៦០០០រៀលក្នុងម្នាក់។

នៅចុងបញ្ចប់នៃកម្មវិធីអ្នកចូលរួមបានបង្ហាញពីការសាទរ ដែលបានចូលរួមក្នុងការស្វែងយល់ពីបញ្ហានានា ដែលស្ត្រីជួបប្រទះតាមរយៈសិល្បៈ និងភាពច្នៃប្រឌិត៕



**« សប្ដាហ៍នៃការសម្អាត...**

ត្រូវទើបអ្នកជួលបន្ទប់បោះសំរាមចោលពាសវាលពាសកាល។

បញ្ហាដែលកម្មការិនីកម្មករទាំងអស់ជួបប្រទះនេះបានជំរុញក្រុមអ្នកស្រាវជ្រាវជាកម្មការិនី កម្មករ មកពីតំបន់ចាក់អង្រែក្រោម តំបន់ទឹកថ្លា តំបន់ពោធិ៍សែនជ័យ តំបន់ព្រៃទា និងតំបន់ជម្ពូវ័ន រៀបចំយុទ្ធនាការសប្ដាហ៍នៃការសម្អាត។ យុទ្ធនាកានេះធ្វើឡើងជារៀងរាល់ថ្ងៃអាទិត្យ នៅតាមតំបន់ដែលពួកគាត់រស់នៅ។

យុទ្ធនាការនេះមានគោលបំណងជំរុញឲ្យកម្មការិនីកម្មកររស់នៅតាមបន្ទប់ជួលចូលរួម ជួយថែរក្សាបរិស្ថានធ្វើយ៉ាងណាឲ្យបរិស្ថានស្អាត និងមានការវេចខ្ចប់សំរាមហើយបោះចោលនៅកន្លែងដែលត្រឹមត្រូវ។ លើសពីនេះយុទ្ធនាការនេះធ្វើឡើងក្នុងគោលបំណងបង្កើនទំនាក់ទំនង និងកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋានដែលនៅតាមតំបន់ទាំងនោះ។

យុទ្ធនាការចាប់ផ្ដើមដំបូងដោយកម្មការិនីកម្មករធ្វើការសម្អាតនៅជុំវិញមណ្ឌលសំចតនៅជុំវិញបន្ទប់ជួល នៅតាមផ្សារដែលនៅក្បែរកន្លែងរស់នៅជាដើម ដោយការរើសសំរាម និងសម្អាតបង្គន់ផងដែរ។

ដោយមើលឃើញពីអត្ថប្រយោជន៍នៃយុទ្ធនាការនេះ កម្មការិនី កម្មករ ដែលរស់នៅតំបន់ទាំងនោះ ក៏ដូចជាម្ចាស់ផ្ទះជួល និងអាជ្ញាធរមូលដ្ឋានជាដើមបានសាទរ និងចូលរួមសកម្មជាមួយគ្នា៕



**« សេចក្ដីសង្ឃឹម...**

តាមកន្លែងដងទឹក និងតាមរយៈសហជីព កម្មការិនីទាំងបីរូបនេះ ក៏បានទៅចុះឈ្មោះភ្លាមៗ ក្នុងនោះមានអ្នកឈរឈ្មោះសរុប ៣២នាក់ ជាតំណាងពេញសិទ្ធិដែលមាន ២៦រូបជាកម្មករ ហើយ៦រូប ទៀតជាប្រធានក្រុម ប្រធានផ្នែក និង បុគ្គលិក និង ៣០រូបជាតំណាងជំនួយ ដែលមាន ២៤រូបជាកម្មករ ហើយ ៦រូប ទៀតជាប្រធានក្រុម ប្រធានផ្នែក និងបុគ្គលិក។ ការបោះឆ្នោតគឺធ្វើដំណើរគ្នារវាងតំណាងពេញសិទ្ធិ និងតំណាងជំនួយ (តំណាងជំនួយនឹងក្លាយជាតំណាងពេញសិទ្ធិ ប្រសិនបើមានតំណាងពេញសិទ្ធិណាមួយឈប់ពីការងារ)។ បន្ទាប់ពីបោះឆ្នោតរួចរាល់ ក៏មានការរាប់សន្លឹកឆ្នោតចំពោះមុខអ្នកដែលបានឈរឈ្មោះទាំងអស់ ប៉ុន្តែមិនមានសមាសភាពក្រសួងការងារនោះទេ។ នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ ២០១៧ ជាលទ្ធផលពួកគាត់ទាំងបីរូបបានទទួលការគ្រាំទ្រ និងបោះឆ្នោតឲ្យជាប់ជាតំណាងកម្មករ ពីកម្មការិនី កម្មករ នៅក្នុងរោងចក្រនេះ ក្នុងចំណោមតំណាងកម្មករពេញសិទ្ធិសរុប ២៣រូប ស្ត្រី ១១រូប និងបុរស ១២រូប ដែលមាន ២១ តំណាងឲ្យកម្មករ និង ២រូបទៀត តំណាងឲ្យប្រធានក្រុម ប្រធានផ្នែក និងបុគ្គលិក៕